


# ពេលសំរាក
# ទៅបោះឆ្នោត

**កន្លែងបោះឆ្នោត បើកពីម៉ោង 7:00 ព្រឹក ដល់ 8:00 យប់ រាល់ថ្ងៃបោះឆ្នោតនិមួយៗ**

បើអ្នកត្រូវនៅឯកន្លែងធ្វើការ ក្នុងអំឡុងពេលនោះ ហើយអ្នកពុំមានពេលគ្រប់គ្រាន់ក្រៅម៉ោងធ្វើការ ដើម្បីទៅបោះឆ្នោត នៅពេលបោះឆ្នោតទូទាំងរដ្ឋ នោះច្បាប់រដ្ឋកាលីហ្វ័រនីញ៉ា អនុញ្ញាតឲ្យអ្នកយក ពេលសំរាកដល់ទៅពីរម៉ោង ដើម្បីទៅបោះឆ្នោត ដោយមិនខាតបង់ប្រាក់កាសអ្វីឡើយ។

អ្នកអាចនឹងយកពេលច្រើនតាមតែអ្នកត្រូវការ ដើម្បីទៅបោះឆ្នោត ប៉ុន្តែចំនួនពីរម៉ោងនៃពេល នោះតែប៉ុណ្ណោះ នឹងបានបើកប្រាក់ឲ្យ។

ពេលសំរាករបស់អ្នក សំរាប់ការបោះឆ្នោត អាច ជានៅពេលចាប់ផ្តើម ឬចុងវេនធ្វើការធម្មតា របស់អ្នកតែប៉ុណ្ណោះ តាមណាមួយដែលមាន ពេលទំនេរច្រើនបំផុតសំរាប់ការបោះឆ្នោត និង អស់ពេលយ៉ាងតិចបំផុត ពីវេនធ្វើការធម្មតារបស់ អ្នក លុះត្រាតែអ្នកធ្វើការរៀបចំផ្សេងទៀត ជាមួយ នឹងនិយោជករបស់អ្នក។

បើសិននៅបីថ្ងៃធ្វើការមុនថ្ងៃបោះឆ្នោត អ្នកគិតថា អ្នកនឹងត្រូវការពេលសំរាកទៅបោះឆ្នោត អ្នកត្រូវ តែជំរាបនិយោជករបស់អ្នក ឲ្យបានយ៉ាងតិចបំផុត ចំនួនពីរថ្ងៃធ្វើការ មុនថ្ងៃបោះឆ្នោត។

# កំណត់ហេតុជូនមកដល់និយោជក ស្តីពីពេលសំរាកនៃនិយោជិត សំរាប់ការបោះឆ្នោត

ច្បាប់រដ្ឋ (ច្បាប់ការបោះឆ្នោតរដ្ឋកាលីហ្វ័រនីញ៉ា វគ្គ 14001) តម្រូវឲ្យនិយោជកបិទប្រកាសកំណត់ហេតុ ជូននិយោជិតរបស់គេ ដោយប្រាប់គេអំពីលក្ខខ័ណ្ឌទាំងពួង សំរាប់ការយកពេលសំរាកបានបើកប្រាក់ឲ្យ សំរាប់គោលបំណងនៃការបោះឆ្នោត ក្នុងការបោះឆ្នោតទូទាំងរដ្ឋ។

គំរូនៃ កំណត់ហេតុនេះ ត្រូវបានផ្ដិតនៅម្ខាងទៀតនៃទំព័រនេះ សំរាប់ជាការងាយស្រួលដល់អ្នក។

បើអាចអនុវត្តបាន កំណត់ហេតុនេះត្រូវតែបានបិទប្រកាសនៅឯកន្លែងធ្វើការដែលអាចមើលឃើញច្បាស់ ឬនៅទីណាទៀតដែលនិយោជិតអាចមើលឃើញ នៅពេលគេទៅមកកន្លែងធ្វើការរបស់គេ ដោយមិនតិចជាង 10 ថ្ងៃ មុនថ្ងៃបោះឆ្នោតទូទាំងរដ្ឋនិមួយៗ ឡើយ។

បើអ្នកមានសំណួរអ្វីអំពីកំណត់ហេតុនេះ ឬព័ត៌មានផ្សេងទៀតទាក់ទងនឹងការបោះឆ្នោត សូមទាក់ទងលេខពិសេសអ្នកបោះឆ្នោត របស់រដ្ឋលេខាធិការ តាមលេខ (888) 345-4917។

និយោជិតអាចបានបើកប្រាក់សំរាប់ពេលសំរាក សំរាប់គោលបំណងនៃការបោះឆ្នោត ដរាបតែបើគេពុំមានពេលគ្រប់គ្រាន់ក្រៅម៉ោងធ្វើការដើម្បីទៅបោះឆ្នោតបានប៉ុណ្ណោះ។ បំណងនៃច្បាប់គឺដើម្បីផ្តល់ ឱកាសឲ្យអាចបោះឆ្នោត សំរាប់កម្មករដែលមិនអាចបោះឆ្នោតបាន ពីព្រោះតែការងាររបស់គេ។

កន្លែងបោះឆ្នោត បើកពីម៉ោង 7:00 ព្រឹក ដល់ 8:00 យប់ រាល់ថ្ងៃបោះឆ្នោតនិមួយៗ។

និយោជិតអាចបានឲ្យពេលច្រើនតាមតែគេត្រូវការដើម្បីទៅបោះឆ្នោត ប៉ុន្តែជាអតិបរិមាតែពីរម៉ោងប៉ុណ្ណោះ ដែលបានបើកប្រាក់ឲ្យ។

និយោជកអាចនឹងតម្រូវឲ្យនិយោជិតផ្តល់កំណត់ហេតុជាមុន ថាគេនឹងត្រូវការពេលសំរាកថែមទៀត សំរាប់ការបោះឆ្នោត។

និយោជកអាចនឹងតម្រូវឲ្យយកពេលសំរាក នៅពេលចាប់ផ្ដើម ឬនៅចុងវេនធ្វើការ របស់និយោជិតតែប៉ុណ្ណោះ។